# ការវិភាគ

## របស់ព្រះតេជព្រះគុណបណ្ឌិតហុក-សាវណ្ណ ក្រោមប្រធានបទ មតិជំទាស់នឹងទស្សនៈរបស់លោក កេង-វ៉ាន់សាក់អំពីព្រះបាទជ័យវរ្ម័នទី៧

website : www.hoksavann.org

ថ្ងៃទី២៥ កុម្ភៈ ២០០៦



អស់កាលជាច្រើនសប្តាហ៍ ដែលវិទ្យុអាស៊ីសេរីបានសម្ភាសលោកកេង-វ៉ាន់សាក់ អំពីអត្តសញ្ញាណខ្មែរ ។ ចម្លើយរបស់គាត់សំអាងទៅលើរឿងព្រេងខ្មែរលើសិលាចារិកលើពាក្យខ្មែរ ហើយកន្លែងខ្លះប៉ាន់ស្មានដោយខ្លួនឯង ។ អ្នកជំនាញការខាងប្រវត្តិសាស្ត្រខ្មែរមានការជំទាស់យ៉ាងខ្លាំង ត្រង់លោកកេង-វ៉ាន់សាក់ពោលតិះដៀលបង្អាប់ព្រះបាទជ័យវរ្ម័នទី៧ អតីតព្រះមហាក្សត្រខ្មែរដែលសោយរាជ្យនៅគ.ស.១១៨១ ថាព្រះអង្គប្រព្រឹត្តអំពើឃោរឃៅ អយុត្តិធម៌ សាហាវ កាប់សម្លាប់ប្រជាពលរដ្ឋ ប្រើមនុស្សឲ្យធ្វើការធ្ងន់ៗ ប្រគល់ដីខ្មែរសុខោទ័យឲ្យទៅថៃ ហើយថាព្រះអង្គជាជនជាតិចាម ដូច្នេះហើយបានជារូបសំណាកព្រះអង្គបានត្រូវគេវាយកំទេចគ្មានសេសសល់ ។ គាត់ពោលទៀតថា លោកលង-ហាប់អាន ធ្វើការនៅពុទ្ធសាសនបណ្ឌិត្យបានដុតចោលនូវឯកសារដែលនិយាយអាក្រក់ពីព្រះបាទជ័យវរ្ម័នទី៧ ។ ទស្សនៈនេះផ្ទុយគ្នាពីទស្សនៈរបស់អ្នកប្រាជ្ញប្រវត្តិសាស្ត្រទាំងខ្មែរនិងបរទេស ព្រមទាំងប្រជាពលរដ្ឋខ្មែរចាត់ទុកព្រះបាទជ័យវរ្ម័នទី៧ ជាក្សត្រមានមហិទ្ធិរិទ្ធដ៏ខ្លាំងអស្ចារ្យ ដែលនៅក្នុងរាជ្យព្រះអង្គជាមហាអំណាច មានទឹកដីធំទូលាយ មានអារ្យធម៌ដ៏រុងរឿង ហើយបានជះឥទ្ធិពលទៅលើប្រទេសជិតខាងទៀតផង ។ ការពោលអះអាងរបស់គាត់ដែលថា លោកលាង-ហាប់អានបានដុតចោលនូវឯកសារ ដែលនិយាយអាក្រក់ពីព្រះបាទជ័យវរ្ម័នទី៧ តើឯកសារនោះអ្នកណាសរសេរ បើលោកសេដិស (Cedés) អ្នកប្រវត្តិសាស្ត្របារាំងសរសេរ គេពុំមែនសរសេរទុកឲ្យតែខ្មែរមួយក្បាលទេ គេពិតយកទៅបោះពុម្ពរាប់រយរាប់ពាន់ក្បាល ដែលធ្វើឲ្យអ្នកស្រាវជ្រាវប្រទះឃើញពុំខាន ដូច្នេះ

ការអះអាងរបស់លោកកេង-វ៉ាន់សាក់ពុំអាចយកជាការបានឡើយ ។ ត្រង់ដែលគាត់ពោលថា ព្រះបាទជ័យវរ្ម័នទី៧បានប្រគល់ដីសុខោទ័យជាដីខ្មែរឲ្យទៅថៃ ក៏រឹតតែពុំត្រឹមត្រូវទៅទៀត ព្រោះព្រះបាទជ័យវរ្ម័នទី៧សោយរាជ្យរវាងសតវត្សទី១១និងទី១២ គឺគ.ស.១១៨១ដល់គ.ស.១២១៨ ឯថៃកើតជាប្រទេសនៅសតវត្សទី១៣ ភូមាកើតជាប្រទេសនៅសតវត្សទី៩ វៀតណាមកើតជាប្រទេសនៅសតវត្សទី១០ ។ អ្នកប្រាជ្ញពិតប្រាកដ មុនគេលើកយកពាក្យណាមកនិយាយ គេតោងស្រាវជ្រាវឯកសារពីប្រភពច្រើនកន្លែង គេតោងពិភាក្សាគ្នា មានធ្វើសិក្ខាសាលាជាដើម ទើបគេសន្និដ្ឋានជាក្រោយ ជាពិសេសបញ្ហាសំខាន់ៗដូចបញ្ហាព្រះបាទជ័យវរ្ម័នទី៧នេះ ដែលប្រជាពលរដ្ឋខ្មែរ ទាំងបរទេសកោតសរសើរអំពីស្នាព្រះហស្តរបស់ព្រះអង្គ ក្នុងការដឹកនាំប្រទេសបានលូតលាស់ចំរើន ។ សំដីរបស់លោកកេង-វ៉ាន់សាក់ធ្វើឲ្យខ្មែរបែកបាក់សាមគ្គីគ្នា ហើយធ្វើឲ្យបរទេសមើលងាយ ។

តាមពាក្យបៀនប្រដៅរបស់ព្រះពុទ្ធ ត្រូវនិយាយក្នុងលក្ខណៈ៥យ៉ាងគឺ ៖ ១- និយាយការពិត, ២- និយាយពាក្យមានប្រយោជន៍, ៣-និយាយតាមកាលគួរនិយាយ ៤- និយាយប្រកបដោយមេត្តា, ៥- និយាយបិយវាចា គឺសំដីទន់ភ្លន់ផ្អែមល្ហែម ។ លោកកេង-វ៉ាន់សាក់មិននិយាយស្របតាមធម៌នេះទេ ។ ធម៌មួយទៀត កុំឲ្យប្រកាន់ជឿអាការៈ១០យ៉ាង មានមិនឲ្យជឿដោយឮឬស្តាប់តាមគ្នា ដោយយល់ថាជារបស់បរមបូរាណ ជឿដោយអាងតម្រាក្បួនច្បាប់ និងជឿដោយនឹកស្មានខ្លួនឯងជាដើម តែមុននឹងជឿថាជាបែបណាមួយ ត្រូវពិចារណាឲ្យបានល្អិតល្អន់ជាមុនសិន ។

ក្នុងការធ្វើការពន្យល់របស់គាត់ កន្លែងខ្លះលោកកេង-វ៉ាន់សាក់ពុំយក«ពាក្យ»មកឲ្យន័យទៅតាមការយល់ឃើញរបស់គាត់ ដូចពាក្យថា«កម្ពុជា» គាត់ថាមកពីក+ពូ+ជា គឺខ្មែរជាកពូជជា មិនដែលធ្វើខ្ញុំគេ ។ តើនេះជាការពិតឬទេ បើខ្មែរធ្លាប់ធ្វើអាណានិគមបារាំងអស់ជិតមួយសតវត្ស ខ្មែរកម្ពុជាក្រោមនៅក្រោមការត្រួតត្រារបស់វៀតណាម ហើយសព្វថ្ងៃនេះមានខ្មែរខ្លះទៅស៊ីឈ្នួលធ្វើខ្ញុំគេនៅប្រទេសម៉ាឡេស៊ី នៅចិន នៅថៃ នៅកូរ៉េជាដើម ។ កម្រមានពាក្យពិតទៅតាមពិតណាស់ ដូចគេដាក់ឈ្មោះមនុស្សថា «រស់» ពុំមែនមនុស្សនោះពុំស្លាប់ទេ ក៏ដូចមនុស្សឈ្មោះ «ជា» ពុំមែនមនុស្សនោះពុំឈឺឡើយជាដើម ។ តាមពិតការដាក់ឈ្មោះនេះ ជាសម្មតិសច្ចៈ ជាការសន្មត់ ពុំមែនពិតទៅតាមឈ្មោះនោះទេ គឺការដាក់ឈ្មោះសំរាប់ហៅគ្នាទៅវិញទៅមកកុំឲ្យច្រឡំគ្នាប៉ុណ្ណោះ ។ ផ្ទុយទៅវិញ បរមត្ថសច្ចៈទើបពិតទៅតាមពាក្យនោះ ដូចជាពាក្យថា«រូប»ដែលឲ្យន័យថា ធម្មជាតិណាដែលកើតឡើងហើយវិនាសទៅវិញ ធម្មជាតិនោះហៅថា«រូប» ។ ពាក្យថា«និព្វាន»ប្រែថាការរលត់តណ្ហាជាដើម ។ កន្លែងខ្លះ លោកកេង-វ៉ាន់សាក់ឲ្យន័យដោយការនឹកស្មាន ដូចប្រាសាទអង្គរវត្តបែរមុខទៅទិសខាងលិច គាត់យល់ថាមកពីក្រុមជាងទាំងនោះប្រឆាំងនឹងស្តេច ។ បានជាថាគាត់នឹកស្មាន ព្រោះគ្មានឯកសារណាសរសេរដូចគាត់

យល់នោះទេ ។ លោកកេង-វ៉ាន់សាក់បានវែកញែករឿងព្រេងខ្មែរ រឿងរាមកេរ្តិ៍សុទ្ធសឹងជារឿងប្រឌិត (fiction) បែបអក្សរសិល្ប៍ មកធ្វើជារឿងប្រវត្តិសាស្ត្រ (history) ជារឿងពិតដែលទាក់ទងអត្តសញ្ញាណខ្មែរ ដូចជាគាត់ពោលថា ខ្មែរពីដើមគោរពក្រពើ គោរពនាគ ដូចជារូបចម្លាក់តាមព្រះវិហារគេដាក់រូបនាគ ។ តាមពិតខ្មែរដាក់រូបនាគតាមក្លោងទ្វារ តាមហោជាងនៃព្រះវិហារនោះ គ្រាន់តែជាគ្រឿងលំអ ពុំមែនជាសក្ការៈបូជាឡើយ ។ គាត់ដោះស្រាយរឿងរាមកេរ្តិ៍ខ្មែរ ដែលចេញមកពីរឿងរាមាយណៈឥណ្ឌា ជារឿងសាសនាហិណ្ឌូនិកាយវិស្ណុ ហើយខ្មែរយកមកតែងជារឿងរាមកេរ្តិ៍ ហាក់ដូចជារឿងពិតតាមប្រវត្តិសាស្ត្រ តាមការពន្យល់របស់គាត់ ។ ផ្នែកអក្សរសាស្ត្រ កូនសិស្សរបស់គាត់បានកែប្រែអក្សរជាច្រើន ពាក្យសម័យរដ្ឋកម្ពុជាអំឡុងឆ្នាំ១៩៨០ អក្សរ«ឡ»និងអក្សរ«ណ»ស្ទើរលុបចោលទៅហើយ ។ គាត់មិនចូលចិត្តបាលីនិងសំស្ក្រឹតឡើយ ដែលជាពាក្យកម្ចីយកមកប្រើក្នុងភាសាខ្មែរដែលខ្វះខាត ។ គាត់ចង់រក្សាទុកតែពាក្យខ្មែរសុទ្ធ ។ តាមពិតគ្រប់ភាសាទាំងអស់ក្នុងលោក ជាពិសេសភាសាបារាំងនិងអង់គ្លេស ដែលចាត់ទុកជាភាសាអន្តរជាតិ ក៏ជៀសមិនផុតពីការខ្ចីភាសាក្រិកនិងឡាតាំងខ្លះមកប្រើដែរ ។ តាមសម្តេចព្រះសុមេធាធិបតីសម្តេចជួន-ណាតព្រះសង្ឃរាជគណៈមហានិកាយគង់នៅ ចោទលោកកេង-វ៉ាន់សាក់ថា ជាមេក្រមីអក្សរសាស្ត្រ ។ តាមពត៌មានពីរាជបណ្ឌិតសភាកម្ពុជានិងក្រសួងវប្បធម៌ថា បានប្រកាសឲ្យប្រើអក្សរតាមវចនានុក្រមជួន-ណាត ហើយការកែប្រែអក្សរខ្លះក្នុងសម័យរដ្ឋកម្ពុជានោះ ត្រូវត្រឡប់មកសរសេរដូចដើមវិញ ។ ផ្នែកវប្បធម៌វិញ លោកកេង-វ៉ាន់សាក់មិនគាំទ្រព្រះពុទ្ធសាសនានិងសាសនាហិណ្ឌូ ដែលជាវប្បធម៌ឥណ្ឌាចូលមកប្រទេសកម្ពុជា គាត់ចង់រក្សាទុកអ្វីដែលជាខ្មែរសុទ្ធ ដូចខ្មែរជំនាន់ដើមគោរពអារក្សអ្នកតា ហើយសាសនារបស់គាត់គឺសាសនាជី ៖ មេបា ព្រះ តា ចៅ ។ ត្រង់គំនិតនេះហើយ បានជាគាត់ពោលកាលពីឆ្នាំមុននេះថា ជាយូរឆ្នាំហើយគាត់បានធ្វើដំណើរទៅកម្ពុជាក្រោម បានឃើញព្រះសង្ឃគូរគំនូរសត្វនរក គាត់ថាជាការបោកបញ្ឆោតឲ្យមនុស្សខ្លាចយកចង្ហាន់មកប្រគេន ។ នេះជាការបន្ទុះបង្អាប់ព្រះពុទ្ធសាសនារបស់លោកកេង-វ៉ាន់សាក់ ។ តាមពិតសត្វដែលទៅសោយទុក្ខក្នុងនរកពិតជាមាន ជាតួព្រះពុទ្ធដិកាសំដែងក្នុងអភិធម្ម អំពីអបាយភូមិទាំង៤គឺ នរក ប្រេត តិរច្ឆាន និងអសុរកាយ មានស្ថានពិតប្រាកដ ប៉ុន្តែមនុស្សធម្មតាពុំអាចមើលឃើញ មើលឃើញបានចំពោះអ្នកមានទិព្វចក្ខុ ។ ប៉ុន្តែលោកកេង-វ៉ាន់សាក់បដិសេធ ព្រោះគាត់ចេះតែផ្លូវលោក ពុំបានសិក្សាស្រាវជ្រាវនិងធ្វើការពិសោធតាមផ្លូវចិត្ត ។

តាមការសិក្សាស្រាវជ្រាវមក លោកកេង-វ៉ាន់សាក់ជាសាស្ត្រាចារ្យផ្នែកអក្សរសាស្ត្រ ជាគ្រូរបស់ពួកខ្មែរក្រហម កាលជំនាន់ខ្មែរក្រហមមិនទាន់បានអំណាច ពួកខ្មែរក្រហមតែងទុកគាត់ជាគ្រូ មានចម្ងល់អ្វីមួយ តែងទៅសួរគាត់ ហើយគាត់ជាអ្នក

ជាតិនិយមម្នាក់ ប៉ុន្តែជាតិនិយមជ្រុល (radical, extrême) ម៉្លោះហើយបានជានៅពេលដែលខ្មែរក្រហមជាកូនសិស្សគាត់បានឡើងកាន់អំណាច បានកំទេចចោលដូចជាផ្នែកវប្បធម៌ សាសនា ប្រពៃណី ទំនៀមទំលាប់ដ៏ល្អ ថាជារបស់សក្តិភូមិ មូលធន និងរបស់ចក្រពត្តិ ។ អ្នកសិក្សាបានជ្រាបហើយថា វប្បធម៌បើនៅនឹងមួយកន្លែង គ្មានការអភិវឌ្ឍន៍ទេ ជាវប្បធម៌ស្លាប់ ដូចខ្មែរពីដើមជឿអារក្សអ្នកតា ដូចជាជំនឿមនុស្សក្នុងលោកដែរ ដូចជឿវត្ថុធម្មជាតិ ថាឲ្យសុខឲ្យទុក្ខ ក៏កើតការបន់ស្រន់បួងសួងអង្វរករសុំសេចក្តីសុខ ។ ឆ្លងមកការពិសោធន៍អស់ពេលដ៏យូរមក មនុស្សលោកជាពិសេសជនជាតិខ្មែរក៏ផ្លាស់ជំនឿដើមនេះ មកជឿការងារខ្លួនឯងវិញ ជាពិសេសពេលដែលព្រះពុទ្ធសាសនាចូលមក ជនជាតិខ្មែរក៏ទទួលយកមកសិក្សារៀនសូត្រនិងប្រតិបត្តិតាមភ្លាម ព្រោះជាសាសនាមានសច្ចភាព ដឹកនាំមនុស្សសត្វឲ្យចេញចាកទុក្ខផង ហើយស្របតាមគំនិតរបស់ខ្លួនផង ។ បើយើងនៅមានៈប្រកាន់ថា មិនទទួលយកពុទ្ធសាសនាមកកាន់ទេ ព្រោះព្រះពុទ្ធសាសនាជារបស់ឥណ្ឌា ពុំមែនជារបស់ខ្មែរទេ របស់ខ្មែរឬជំនឿខ្មែរគឺអារក្សអ្នកតា តើបែបនេះមានការជឿនលឿនខាងគំនិតបញ្ញាឬទេ ? តាមពិត ព្រះសម្ពុទ្ធជាព្រះពុទ្ធរបស់មនុស្សលោក ត្រាស់ដឹងដើម្បីប្រយោជន៍មនុស្សលោក ព្រោះសច្ចៈដែលព្រះអង្គត្រាស់ដឹង ជាសច្ចៈសាកល ដូចពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធ បានបុណ្យគុណទោសសុខទុក្ខចំរើនវិនាស គ្រប់ជនជាតិអាចយកទៅសិក្សានិងអនុវត្តតាមបាន សុខចំរើនដូចគ្នា មិនមែនសំរាប់តែជនជាតិឥណ្ឌានោះទេ ។ ឧទាហរណ៍ជាក់ស្តែងអំពីយានជំនិះ ពីដើមខ្មែរយើងធ្វើដំណើរដោយថ្មើរជើង ឬដោយជិះរទេះគោ ឥឡូវនេះមានរថយន្ត មានអយស្ម័យយាន មានអាកាសយាន បើយើងនៅកាន់របស់បូរាណ យើងនៅតែដើរនៅតែជិះរទេះគោ កុំជិះរបស់ទំនើបដែលគេរកឃើញថ្មីៗនេះ ព្រោះពុំមែនជារបស់ខ្មែរទេ ។ សហរដ្ឋអាមេរិក កាណាដា បារាំងដែលជឿនលឿននោះ ដោយសារអ្នកចំណូលថ្មីដែលមានអារ្យធម៌ខ្ពស់ មានបញ្ញាខ្ពស់ ធ្វើឲ្យប្រទេសតាំងនោះមានការល្បូតលាស់ខាងវប្បធម៌ សេដ្ឋកិច្ច និងនយោបាយ គ្រាន់បើជាងជនជាតិដើម ។ ចំណែកប្រជាពលរដ្ឋខ្មែរដែលទទួលយកព្រះពុទ្ធសាសនាមកគោរពតាមនោះ គឺប្រតិបត្តិឲ្យស្របតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធផង ឲ្យស្របតាមចិត្តគំនិតទំនៀមទំលាប់របស់ខ្លួនផង ដែលទំរើនេះធ្វើឲ្យផ្សេងគ្នាពីពុទ្ធសាសនាថៃ ភូមា និងស្រីលង្កា ពិតមែនតែពុទ្ធសាសនាថេរវាទដូចគ្នា ។ បានសេចក្តីថា ខ្មែរទទួលយកវប្បធម៌អំពីខាងក្រៅយកមកឆ្នៃរចនាស្របទៅតាមផ្នត់គំនិតរបស់ខ្លួន ។ តួអក្សរខ្មែរសព្វថ្ងៃនេះ យកតាមលំនាំអក្សរទេវនាគរីតួអក្សរសំស្រ្កឹត ប៉ុន្តែបានកែប្រែតួរហូតដល់១១ដងទើបបានរាងរៅដូចតួសព្វថ្ងៃ ហើយថៃយកតួអក្សរខ្មែរនេះ ទៅឆ្នៃកែតទៅទៀត ទើបបានជាតួអក្សររបស់ជាតិគេប្រើសព្វថ្ងៃ ។ ដូច្នេះបញ្ជាក់ថា អក្សរសាស្រ្តដែលអភិវឌ្ឍន៍នោះ គឺទទួលយករបស់គេដែលស្របនឹងគំនិតខ្លួន មកឆ្នៃរចនាឲ្យទៅជារបស់

ខ្លួន ។ ចំពោះប្រាសាទសីលារាប់ពាន់នៅកម្ពុជា ដែលសាងឡើងឧទ្ទិសចំពោះព្រះឥសូរព្រះវិស្ណុ ដែលនាំចូលមកពីប្រទេសឥណ្ឌានោះ បើពិនិត្យមើលស្ថាបត្យកម្មនិងបដិមាកម្ម ពុំមែនលក្ខណៈណាដូចនៅប្រទេសឥណ្ឌាឡើយ ។ ដូច្នេះបញ្ជាក់ថា ទោះបីខ្មែរយកភាគខ្លះពីគេ ក៏យកមកឆ្នៃតាមលក្ខណៈរបស់ខ្លួន ។

ដូចបានពោលមកហើយ ដើម្បីឲ្យមានយុត្តិធម៌ត្រូវឈរជំហរកណ្តាល កុំឲ្យលំអៀងដូចចៅក្រមត្រឹមត្រូវកាត់សេចក្តី យ៉ាងណាមិញ បញ្ហាព្រះបាទជ័យវរ្ម័នទី៧ជាអ្នកដឹកនាំល្អ ដូចដែលអ្នកប្រវត្តិសាស្ត្រជាតិនិងអន្តរជាតិកោតសរសើរ ឬជាអ្នកដឹកនាំអាក្រក់ដូចទស្សនៈលោកកេង-វ៉ាន់សាក់តែម្នាក់ឯងដែលពោលកន្លងមកនេះ កុំឲ្យស្អប់ស្តេចចេះតែរកកំហុសស្តេច ស្អប់សាសនាចេះតែរកកំហុសសាសនា នោះពុំមែនជាគតិបណ្ឌិត្យដែលត្រូវប្រកាន់យកទេ ។ គំនិតជាតិនិយមជ្រុលធ្វើឲ្យខ្មែរបែកបាក់គ្នាថែមទៀត ហើយពុំអាចឲ្យខ្មែរដើរទៅមុខ ក្នុងភាពថ្លៃថ្នូរនិងជឿនលឿនផង ។ ជាតិនិយមជ្រុលបានសេចក្តីថា ទៅរកគំនិតខ្មែរពីដើម ហើយពុំទទួលស្គាល់គំនិតខ្មែរជឿនលឿន មានការវិវត្តិន៍ទៅរកការចំរើន ដូចជាជនជាតិខ្មែរគោរពព្រះពុទ្ធសាសនា ស្ទើររលាយជាសាច់ឈាម ជាអត្តសញ្ញាណរបស់ខ្លួនទៅហើយ បែរជាណែនាំខ្មែរឲ្យជឿជំនឿដើម ដែលជាសម័យពុំទាន់មានការជឿនលឿននៅឡើយ ។ ការពោលមកនេះពុំបន្ទោសជនណាឡើយ គ្រាន់តែជាអនុសាសន៍សំរាប់ខ្មែរគ្រប់រូបពិចារណា ។៚

❀ ❀

❀